# ៣. ធ្វើឱ្យការអប់រំមានធនធានរូបវ័ន្ត

ច្បាប់សិទ្ធិមនុស្សអន្តរជាតិសង្កត់ធ្ងន់អំពីទំនួលខុសត្រូវរបស់រដ្ឋក្នុងការធានាផ្តល់ការអប់រំនៅបឋមសិក្សាដោយកាតព្វកិច្ច និងដោយមិនគិតថ្លៃ។ បញ្ញត្តិសំខាន់ៗមួយចំនួនមានបញ្ចូលនៅក្នុងសន្ធិសញ្ញាដូចមានបង្ហាញនៅក្នុងតារាងទី ៤ បង្ហាញពីការកែប្រែនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។[6] ការកែប្រែទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា ការអប់រំនៅតែមិនគិតថ្លៃ និងដោយកាតព្វកិច្ច។

## ៣.១. សកលកម្មការអប់រំ

**តារាង ៤ : បញ្ញត្តិក្នុងសន្ធិសញ្ញាសំខាន់ៗស្តីពីការអប់រំដោយកាតព្វកិច្ច និងមិនគិតថ្លៃ**

***សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)*** : *ការអប់រំនឹងមិនគិតថ្លៃ យ៉ាងហោចណាស់ក៏នៅក្នុងបឋមសិក្សា និងដំណាក់កាលមូលដ្ឋានដែរ។ ការអប់រំគឺជាកាតព្វកិច្ចដែលកុមារត្រូវបំពេញដោយកាតព្វកិច្ច។*

***អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស កិច្ចព្រមព្រៀង (១៩៥២)*** : *គ្មានបុគ្គលណាមួយនឹងត្រូវគេបដិសេធមិនឲ្យចូលរៀននោះទេ។*

***អនុសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ (១៩៦០)*** : *ភាគីរដ្ឋនៅក្នុងអនុសញ្ញានេះត្រូវបង្កើត អភិវឌ្ឍ និងអនុវត្តគោលនយោបាយជាតិដែល ... នឹងព្យាយាម ជំរុញសមភាព កាលានុប្បវត្ត និងទង្វើរនានា និងជាពិសេស ក) ធ្វើឲ្យការអប់រំក្លាយជាភារកិច្ច ដែលកុមារត្រូវបំពេញដោយកាតព្វកិច្ច និងមិនបង់ថ្លៃ។*

***កិច្ចព្រមព្រៀងនៃ*** San Salvador ***អនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស (១៩៨៨)*** : *ភាគីរដ្ឋនៅក្នុងកិច្ចព្រមព្រៀងនេះទទួលស្គាល់ថា ដើម្បីអនុវត្តសិទ្ធិទទួលការអប់រំឲ្យបានពេញលេញ ការអប់រំនៅបឋមសិក្សាត្រូវតែជាភារកិច្ចដែលកុមារត្រូវបំពេញដោយកាតព្វកិច្ច និងដោយមិនបង់ថ្លៃ។*

***អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩)*** : *ភាគីរដ្ឋទទួលស្គាល់សិទ្ធិកុមារក្នុងការអប់រំ និងដោយមានគំនិតសំរេចឲ្យបាននូវការអនុវត្តសិទ្ធិ និងដោយឈរលើមូលដ្ឋាននៃឱកាសស្មើភាពគ្នា ភាគីរដ្ឋត្រូវ ក) ធ្វើឲ្យការអប់រំក្លាយជាភារកិច្ចដែលកុមារទាំងអស់ត្រូវបំពេញដោយកាតព្វកិច្ច និងមិនបង់ថ្លៃ។*

***ធម្មនុញ្ញាស្តីពីសិទ្ធិ និងសុខុមាលភាពរបស់កុមារអាហ្វ្រិក (១៩៩០)*** : *ភាគីរដ្ឋនៅក្នុងធម្មនុញ្ញបច្ចុប្បន្ននឹងចាត់វាល់វិធានការសមស្របក្នុងគោលបំណងអនុវត្តសិទ្ធិទទួលការអប់រំ និង ក) ធ្វើឲ្យការអប់រំនៅថ្នាក់មូលដ្ឋានមានលក្ខណៈខានមិនបាន និងមិនគិតថ្លៃ។*

***ធម្មនុញ្ញាអឺរ៉ុប(កែសម្រួលហើយ) (១៩៩៦)*** : *ដោយមានគោលបំណងធានាអនុវត្តសិទ្ធិកុមារ និង យុវជនឲ្យមានប្រសិទ្ធភាព និង ឲ្យមានការលូតលាស់នៅក្នុងបរិយាកាសមួយដែលជំរុញឲ្យមានការលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈ និងប្រាជ្ញាស្មារតី និងរាងកាយ ភាគីរដ្ឋ ដោយមានការសហការជាមួយឯកជននឹងចាត់វិធានការសមស្រប និងចាំបាច់ .... ២) ដើម្បីផ្តល់ឲ្យកុមារ និងយុវជននូវការអប់រំបឋមសិក្សា និងមធ្យមសិក្សាដោយកាតព្វកិច្ច និងមិនគិតថ្លៃ និងលើកទឹកចិត្តឲ្យមានការចូលរៀនបានទៀតទាត់។*

គេឃើញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងភាពក្រីក្រ ក្នុងចំណោមគ្រួសារ សហគមន៏ និងប្រទេសទាំងមូលជាមួយនឹងកំរិតអប់រំក្នុងចំណោមកុមារ។ ការកត់សំគាល់ឧបសគ្គហិរញ្ញវត្ថុក្នុងការផ្តល់ការអប់រំបឋមសិក្សាជាសកលគឺជាដំណាក់កាលដ៏សំខាន់ដំបូងក្នុងការលុបបំបាត់ឧបសគ្គក្នុងការសិក្សា។ នេះត្រូវបានកំណត់ដោយស្តង់ដាសិទ្ធិមនុស្សសកលលោកដែលបញ្ជាក់ថា ការអប់រំនៅបឋមសិក្សាត្រូវតែខានមិនបាន និងមិនគិតថ្លៃ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ច្បាប់មិនអាចបង្ខំឪពុកម្តាយ និងរដ្ឋាភិបាលឲ្យផ្តល់ការអប់រំសំរាប់ទាំងអស់គ្នា

---

*[6] អនុសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំបញ្ជាក់យ៉ាងច្បាស់ថា ការអប់រំនៅបឋមសិក្សាត្រូវតែមិនគិតថ្លៃ និងដោយកាតព្វកិច្ច។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ចែងថា "ការអប់រំនៅបឋមសិក្សាត្រូវតែសិក្សាខាន មិនបាននិងដោយមិនគិតថ្លៃសំរាប់ជនគ្រប់រូប"។ អនុសញ្ញាស្តីពីសិទ្ធិ កុមារកំណត់ការអប់រំដោយកាតព្វកិច្ច និងមិនគិតថ្លៃសំរាប់ទាំងអស់គ្នាជាកាតព្វកិច្ចរបស់រដ្ឋទាមទារឲ្យរដ្ឋាភិបាលសំរេចឲ្យបាននូវសិទ្ធិកុមារក្នុងការអប់រំលើមូលដ្ឋាននៃឱកាសសមភាពគ្នា។*

បានទេ បើសិនជាវាហួសពីសមត្ថភាព។ ដូច្នេះ ច្បាប់សិទ្ធិមនុស្សអន្តរជាតិកំណត់នូវវិធីសាស្ត្រជាដំណាក់កាលបន្តបន្ទាប់ដើម្បីបំពេញសិទ្ធិទទួលការអប់រំ។ ការធ្វើបែបនេះនឹងជំរុញឲ្យមានបញ្ញត្តិនៃការអប់រំបឋមសិក្សាដោយកាតព្វកិច្ច និងមិនគិតថ្លៃសំរាប់កុមារទាំងអស់ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

### ការអប់រំដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច

កិច្ចសហការអន្តរជាតិជាការចាំបាច់ ហើយបង្ហាញពីការអនុវត្តជាសកលនូវសិទ្ធិទទួលការអប់រំ។ កាក់នៃសិទ្ធិមនុស្សមានពីរខាង : ម្ខាងនិយាយពីសិទ្ធិអ្វីខ្លះដែលមនុស្សម្នាក់ៗអាចសង្ឃឹមថានឹងបានទទួល —ករណីនេះសិទ្ធិក្នុងការចូលរៀន និងទទួលការអប់រំដែលមានគុណភាព។ ម្ខាងទៀតនិយាយអំពីតួនាទី និងកាតព្វកិច្ចដែលមនុស្សគ្រប់ៗរូប និងរដ្ឋាភិបាលគួរតែធ្វើក្នុងការផ្តល់ និងទ្រទ្រង់សេវាអប់រំ។

ប្រវត្តិសាស្ត្របង្ហាញថា ការអប់រំរបស់កុមារទាំងអស់ជាតួនាទីរបស់រដ្ឋ ពីព្រោះគេមើលឃើញថាការអប់រំគឺជាការវិនិយោគមួយដ៏សំខាន់នៃការរីកចំរើនខាងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសជាតិទៅថ្ងៃអនាគត និងពិសេសជាងនេះទៀត ការអប់រំរួមជាមួយផ្នែកផ្សេងៗទៀតនឹងកំណត់ទិសដៅរបស់ប្រទេសជាតិ។ ការអប់រំដោយផ្អែកលើសិទ្ធិផ្តល់អាទិភាពដល់ការអប់រំនៅបឋមសិក្សារបស់កុមារទាំងអស់ ដោយចាំបាច់តម្រង់ទិសនៃការជ្រើសរើសផ្នែកនយោបាយ ដែលអាចនឹងយកចិត្តទុកដាក់លើវិស័យអប់រំមិនបានដិតដល់។ វិធីនេះក៏ទទួលស្គាល់ផងដែរថា ដោយកុមារខ្វះសំលេងនយោបាយ កុមារត្រូវប្រឹងប្រែងរួមគ្នាដើម្បីធានាផ្តល់ការអប់រំដែលមានគុណភាពតាមរយៈដំណើរការនយោបាយ។

ប្រទេស និងតំបន់នីមួយៗស្ថិតនៅក្នុងដំណាក់កាលខុសគ្នានៅក្នុងដំណើរឆ្ពោះទៅអនុម័ត និងពង្រឹងការធានាសិទ្ធិមនុស្ស។ អាស៊ីគឺជាតំបន់ដែលត្រូវបង្កើតប្រព័ន្ធសិទ្ធិមនុស្សអន្តររដ្ឋាភិបាលដោយនៅយឺតយ៉ាវជាងអាហ្វ្រិក អាមេរិក និងអឺរ៉ុប។ ការផ្តួចផ្តើមគំនិតបានធ្វើរួចមកហើយនៅក្នុងកំរិតអនុតំបន់[7] ដែលគេមានបំណងលុបបំបាត់នូវគម្លាតនេះ។

តាមរយៈយន្តការសិទ្ធិមនុស្សប្រចាំតំបន់ ស្តង់ដាសិទ្ធិមនុស្សសកល –ដែលកំណត់ស្តង់ដាអប្បបរមាសកល – ត្រូវបានកែសម្រួលឲ្យសមស្របតាមកាលៈទេសៈជាក់ស្តែងរបស់តំបន់នីមួយៗ។ គោលនយោបាយត្រូវបានអនុម័តដោយអង្គការសិទ្ធិមនុស្សទាំងបីដែលពង្រឹងសកលកម្មនៃសិទ្ធិអប់រំ និងបំពេញបន្ថែមនូវស្តង់ដាសកល អប្បបរមា តាមរយៈការធ្វើច្បាប់ និងពង្រឹងច្បាប់តំបន់។ ដំណើរការនេះត្រូវបានអនុវត្តបានច្រើនជាងនេះនៅក្នុងប្រទេសនីមួយៗ។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិកំណត់ថា ការការពារសិទ្ធិមនុស្សគឺជាអាទិភាពរបស់ជាតិ។ អង្គការសិទ្ធិមនុស្សអន្តរជាតិដើរតួនាទីជាយន្តការនៃការថ្លឹងថ្លែង តែនៅក្នុងករណីដែលប្រព័ន្ធរបស់ជាតិមិនបានធានានូវស្តង់ដាសិទ្ធិមនុស្សសកល។ សភាពបែបនេះអាចកើតមានដោយសារកង្វះឆន្ទៈនយោបាយក្នុងជួរអ្នកដឹកនាំនៅក្នុងប្រទេស ប៉ុន្តែ ករណីបែបនេះកំពុងតែធ្លាក់ចុះជាបណ្តើរៗហើយ។

នៅពេលខ្លះឆន្ទៈនយោបាយអាចខ្លាំងក្លា តែធនធានចាំបាច់សំរាប់ការពារសិទ្ធិមនុស្សអាចខ្វះខាត។ ភាពក្រីក្រអាចជាឧបសគ្គរបស់ប្រទេសក្នុងការបំពេញកាតព្វកិច្ចឆ្ពោះទៅរកការអប់រំនៅបឋមសិក្សាដោយកាតព្វកិច្ច និងមិនគិតថ្លៃ។ សភាពការណ៍កាន់តែលំបាកទៅទៀតនៅក្នុងប្រទេសដែលមានប្រជាជនវ័យក្មេងៗច្រើន។ កុមារគ្រប់អាយុចូលរៀនអាចមានចំនួនរហូតដល់មួយភាគបីនៃប្រជាជនទាំងមូលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលនៅប្រទេសអភិវឌ្ឍន៍ចំនួនក្មេងគ្រប់អាយុចូលរៀនអាចមានចំនួនតែមួយភាគដប់ប៉ុណ្ណោះ។

ការអប់រំបឋមសិក្សាគួរតែមិនគិតថ្លៃសំរាប់កុមារ ពីព្រោះកុមារមិនអាចបង់ថ្លៃបានទេ ហើយកុមារត្រូវបានច្បាប់ហាមឃាត់មិនឲ្យធ្វើការទៀតផង។ ច្បាប់កំណត់អាយុដែលត្រូវឈប់រៀន និងអាយុដែលអាច

[7] Towards an ASEAN Human Rights Mechanism: Proposal, Declarations and Related Documents, Working Group for an ASEAN Human Rights Mechanism, 1999.

ធ្វើការបាន។ ការមានសេរីភាពមិនទទួលខុសត្រូវចំពោះការងារ មនុស្សពេញវ័យគឺជាលក្ខណៈពិសេសមួយនៃកុមារ ភាព។ ការនេះមិនមែនមានន័យថាការអប់រំមិនគិតថ្លៃ ចំពោះឳពុកម្តាយ សហគមន៍ និងសង្គមនោះទេ។ ពុំមានសិទ្ធិមនុស្សណាដែលមិនគិតថ្លៃនោះទេ។ ដើម្បីលុបបំបាត់អំពើមិនគប្បីរបស់ប៉ូលិស គេត្រូវមានប៉ូលិសដែលមានប្រាក់ខែគ្រប់គ្រាន់។ សេរីភាពនៃការទទួលព័ត៌មានមិនអាចធ្វើទៅបានដោយគ្មានថវិកាគ្រប់គ្រាន់ដើម្បីផ្សព្វផ្សាយព័ត៌មាននោះទេ។ តុលាការមិនអាចឯករាជ្យបានទេ បើមិនបានប្រាក់ខែគ្រប់គ្រាន់។

បុគ្គលម្នាក់ៗមិនគួរចំណាយប្រាក់សំរាប់ការពារផ្ទះរបស់គេឲ្យរួចផុតពីអគ្គីភ័យនោះទេ សេវាបែបនេះគួរតែត្រូវទទួលការឧបត្ថម្ភពីការបង់ពន្ធសាធារណៈ។ ការបង់ប្រាក់ទៅឲ្យតុលាការដោយផ្ទាល់បង្ហាញពីការពុករលួយជាជាងតម្លៃប្រឹក្សាផ្លូវច្បាប់។ ការព្រមព្រៀងគ្នាជាសកលអំពីសេវាដែល រដ្ឋាភិបាលគួរផ្តល់ឲ្យពលរដ្ឋមានបញ្ជាក់នៅក្នុងច្បាប់ដែលកំណត់តួនាទីរបស់រដ្ឋ របស់ពលរដ្ឋ និងសិទ្ធិមនុស្ស។

### ៣.១.១. លទ្ធផលសំរេចបានជាបន្តបន្ទាប់

ប្រទេសផ្សេងគ្នាប្រើប្រាស់គំរូខុសគ្នាដើម្បីធ្វើឲ្យសន្ធិសញ្ញាអន្តរជាតិស៊ីគ្នាជាមួយនឹងគោលនយោបាយជាតិសំរាប់ការអប់រំ។ នៅក្នុងប្រទេសជាច្រើន សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិមិនអាចយកមកអនុវត្តបានទេ។ ឧទាហរណ៍ នៅប្រទេសកម្ពុជា កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិមិនត្រូវបានគេយកមកសំអាងនៅក្នុងតុលាការ ឬអាជ្ញាធររដ្ឋបាលទេ។ ដូចគ្នាដែរនៅប្រទេសសិង្ហបុរី "អនុសញ្ញាអន្តរជាតិ ដូចជាអនុសញ្ញាសិទ្ធិកុមារមិនអាចក្លាយជាផ្នែកមួយនៃប្រព័ន្ធច្បាប់ដោយស្វ័យប្រវត្តិបានទេ។ ដើម្បីឲ្យអនុសញ្ញានេះក្លាយជាផ្នែកមួយនៃប្រព័ន្ធច្បាប់រដ្ឋសភាត្រូវអនុម័តច្បាប់មួយដើម្បីបង្គ្រប់បន្ថែមលើអនុសញ្ញានេះ"។ ចំណែកនៅប្រទេសថៃវិញ "រដ្ឋសភាមានតួនាទីពិនិត្យច្បាប់ដែលទាក់ទងនឹងសិទ្ធិកុមារឡើងវិញដើម្បីធានាថា ច្បាប់ទាំងនោះស៊ីគ្នាជាមួយនឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ"។[៨]

រដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ គោលនយោបាយ និងការអនុវត្តត្រូវបានធ្វើឲ្យស៊ីគ្នាជាមួយនឹងសន្ធិសញ្ញាអន្តរជាតិនៅមានកំរិតខុសៗគ្នាយ៉ាងខ្លាំងរវាងប្រទេស និងប្រទេស។ មានករណីជាច្រើននៅជុំវិញពិភពលោកដែលរដ្ឋធម្មនុញ្ញជាតិមិនបំពេញបន្ថែមឲ្យច្បាប់សិទ្ធិមនុស្សអន្តរជាតិឲ្យបានគ្រប់គ្រាន់។ ផែនការសកលលោកមានបញ្ចូលស្តង់ដាអប្បបរមាដោយទុកឲ្យប្រទេសនានាជ្រើសរើសវិធីសាស្ត្រដើម្បីសំរេចឲ្យបានស្តង់ដាទាំងនោះ។ ការសហប្រតិបត្តិការអន្តរជាតិត្រូវបានគេមើលឃើញថា ជាកត្តាគន្លឹះដែលនឹងជួយឲ្យសំរេចបានសិទ្ធិទទួលការអប់រំ។ ជំនះរាល់ឧបសគ្គក្នុងការធ្វើឲ្យមាននីយកម្មរវាងច្បាប់ជាតិ និងការអនុវត្តជាក់ស្តែងជាមួយនឹងស្តង់ដាអន្តរជាតិរួមបញ្ចូលទាំងជំនួយដល់រដ្ឋាភិបាលដែលមិនទាន់អាចប្រែក្លាយច្បាប់ទាំងនោះឲ្យទៅជាការអនុវត្តបាននៅឡើយ។ ទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងគោលដៅការអប់រំសំរាប់ទាំងអស់គ្នាតម្រូវឲ្យមានផែនការជាតិ។[៩]

---

[8] *U.N.Docs. CERD/C/292/Add. 2, 1997, para. 18; CRC/C/11/Add. 13, para. 67.*

9 *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌តម្រូវឲ្យភាគីនីមួយៗដែលមិនទាន់ធានាបាននូវការអប់រំដោយខានមិនបាន និងដោយមិនគិតថ្លៃសំរាប់ទាំងអស់គ្នាបង្កើត និងអនុម័តលើផែនការសកម្មភាពពិស្តារសំរាប់ការអនុវត្តជាបណ្តើរៗ។ គ្រប់ខ័ណ្ឌសកម្មភាពក្រុងដាកាមានបញ្ញត្តិប្រហាក់ប្រហែលគ្នា និងលើសពីនេះបានទទួលស្គាល់ថា "ប្រទេសជាច្រើនកំពុងខ្វះធនធានក្នុងការសំរេចការអប់រំសំរាប់ទាំងអស់គ្នា" ហើយបន្ថែមទៀតថា "គ្មានប្រទេសណាដែលប្តេជ្ញាផ្តល់ការអប់រំសំរាប់ទាំងអស់គ្នាមិនជួបការលំបាកក្នុងការសំរេចគោលដៅដោយសារតែខ្វះធនធាននោះទេ"។*

វិធីសាស្ត្រខុសគ្នារបស់ប្រទេសនីមួយៗត្រូវបានបង្ហាញនៅក្នុងបញ្ញត្តិរដ្ឋធម្មនុញ្ញ។ ដូចដែលមាននៅក្នុងតារាងទី ៥ មានប្រទេសចំនួន ៤៣ ដែលពុំធានាច្បាស់លាស់នៅក្នុង រដ្ឋធម្មនុញ្ញស្ដីពីសិទ្ធិនៅក្នុងការអប់រំ។ ការធានាបែបនេះមិនមានទេនៅក្នុងប្រទេសចំនួន ១៤៤ ទៀត។ ការធានាឲ្យមានសិទ្ធិទទួលការអប់រំនៅក្នុងរដ្ឋធម្មនុញ្ញនៅក្នុងប្រទេសមួយចំនួនបង្ហាញពីការរីកចំរើនក្នុងការអនុវត្តច្បាប់សិទ្ធិ មនុស្សអន្តរជាតិ។

**ការធានាសិទ្ធិទទួលការអប់រំនៅក្នុងរដ្ឋធម្មនុញ្ញ**

តារាងទី ៥ បង្ហាញថា នៅប្រទេសមួយចំនួនសិទ្ធិទទួលការអប់រំកំពុងតែអនុវត្តបានយ៉ាងច្រើន ហើយកិច្ចសហប្រតិបត្តិការអន្តរជាតិកំពុងតែជួយឲ្យមានការរីកចំរើនបែបនេះ។ គោលការណ៍នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារដែលកុមារទាំងអស់ត្រូវទទួលបានការធានាក្នុងការចូលរៀនដោយមិនគិតពីឋានៈផ្លូវច្បាប់របស់កុមារ ឬឋានៈរបស់ឪពុកម្ដាយកំពុងតែត្រូវបានអនុវត្ត។ នៅប្រទេសចំនួន ៣៧ សិទ្ធិទទួលការអប់រំត្រូវបានកំណត់ឲ្យតែពលរដ្ឋស្របច្បាប់ប៉ុណ្ណោះ។ ការមិនបានបញ្ចូលកុមារដែលមិនមែនជាពលរដ្ឋរបស់ប្រទេសឲ្យចូលរៀនគឺជាការបដិសេធសិទ្ធិអប់រំរបស់កុមារ ឬដាក់កុមារឲ្យនៅក្នុងស្ថានភាពមួយខុសពីកុមារដទៃទៀត។

សឹង្ហបូរីផ្ដល់ឧទាហរណ៍មួយ : *"នៅសាលាបឋមសិក្សា សិស្សសឹង្ហបូរី និងកុមារជនជាតសឹង្ហបូរីមិនបង់ថ្លៃសាលាទេ។ កុមារដែលមិនមែនជាពលរដ្ឋសឹង្ហបូរី នៅបឋមសិក្សាត្រូវបង់ថ្លៃសាលាក្នុងអត្រាខុសគ្នា។ កុមារដែលឪពុកម្ដាយរស់នៅជាអចិន្ត្រៃយ៍ អ្នកដែលកាន់ទិដ្ឋាការបំរើការងារ និងបុគ្គលិកស្ថានទូតបង់ថ្លៃ ៣៦ ដុល្លាសឹង្ហបូរី (ប្រហែល ២០ ដុល្លាអាមេរិក) ក្នុងមួយឆ្នាំ។ អ្នកដែលមិនមែនជាពលរដ្ឋសឹង្ហបូរីដទៃទៀត បង់ថ្លៃចំនួន ៩៦០ ដុល្លាសឹង្ហបូរីក្នុងមួយឆ្នាំ។ យ៉ាងណាក៏ដោយ តម្លៃនេះនៅតិចជាងតម្លៃពិតដែលត្រូវចំណាយក្នុងការបង្រៀនសិស្សម្នាក់នៅសាលាបឋមសិក្សា ដែលមួយឆ្នាំអាចអស់តម្លៃរហូតដល់ ២៨៦៥ ដុល្លាសឹង្ហបូរី"*[១០]

**តារាងទី ៥ : ការធានាផ្ដល់សិទ្ធិទទួលការអប់រំនៅក្នុងរដ្ឋធម្មនុញ្ញ**

| ការអប់រំដោយកាតព្វកិច្ច និងមិនគិតថ្លៃសំរាប់ទាំងអស់គ្នា ដែលមានធានានៅក្នុងរដ្ឋធម្មនុញ្ញ | ការធានាតែចំពោះពលរដ្ឋ និងអ្នករស់នៅ |
|---|---|
| Albania, Algeria, Argentina, Australia, Austria, Azerbaijan, Barbados, Belgium, Belize, Bolivia, Bosnia and Herzegovina, Brazil, Bulgaria, Canada, Cape Verde, Chile, China, Colombia, Congo, Brazzaville, Costa Rica, Croatia, Cuba, Denmark, Democratic People's Republic of Korea, Ecuador, Egypt, Estonia, Finland, France, Gambia, Georgia, Germany, Ghana, Haiti, Honduras, Iceland, India, Ireland, Italy, Japan, Latvia, Liechtenstein, Lithuania, Macedonia, Madagascar, Malta, Mauritius, Mexico, Moldova, Netherlands, Norway, Palau, Panama, Paraguay, Peru, Poland, Portugal, Romania, Russia, Rwanda, Saudi Arabia, Senegal, South Africa, Spain, Sri Lanka, Suriname, Sweden, Switzerland, Tajikistan,Thailand, Trinidad and Tobago, Tunisia, Ukraine, United Arab Emirates, United Kingdom, Uruguay, Venezuela, Yugoslavia | Armenia, Bahrain, Cambodia, Chad, Cyprus, Czech Republic, Dominican Republic, El Salvador, Equatorial Guinea, Greece, Grenada, Guatemala, Guyana, Hungary, Jordan, Kazakhstan, Kuwait, Kyrgyzstan, Libya, Luxembourg, Malawi, Mali, Morocco, New Zealand, Nicaragua, Philippines, Qatar, Republic of Korea, Sao Tome, Seychelles, Slovakia, Slovenia, Syria, Turkey, Turkmenistan, Viet Nam, Yemen |
| **ការធានាជាបណ្ដើរៗ ឬ ដោយផ្នែក** | **គ្មានការធានានៅក្នុងរដ្ឋធម្មនុញ្ញ** |
| Bangladesh, Belarus, Benin, Bhutan, Burma, Cameroon, Comoros, Guinea, Guinea-Bissau, Iran, Iraq, Israel, Maldives, Micronesia, Monaco, Mongolia, Namibia, Nepal, Nigeria, Pakistan, St Kitts and Nevis, Sierra Leone, Sudan, Tanzania, Togo, Uganda, Uzbekistan, Zimbabwe | Angola, Antigua and Barbuda, Bahamas, Botswana, Brunei, Burkina Faso, Burundi, Central African Rep., Cote d'Ivoire, Djibouti, Dominica, Eritrea, Ethiopia, Fiji, Gabon, Indonesia, Jamaica, Kenya, Kiribati, Laos, Lebanon, Lesotho, Liberia, Malaysia, Marshall Islands, Mauritania, Mozambique, Nauru, Niger, Oman, Papua New Guinea, St Lucia, St Vincent, Samoa, San Marino, Singapore, Solomon Islands, Swaziland, Tonga, Tuvalu, USA, Vanuatu, Zambia |

10 Initial report of Singapore, under the Convention on the Rights of the Child, April 2002.

រដ្ឋធម្មនុញ្ញគ្រាន់តែរៀបចំក្របខ័ណ្ឌទូទៅនៃសិទ្ធិមនុស្ស និងកាតព្វកិច្ចដែលពាក់ព័ន្ធនឹងវិស័យអប់រំតែប៉ុណ្ណោះ។ ទំនួលខុសត្រូវក្នុងការផ្តល់ការអប់រំត្រូវចែករំលែករវាងរដ្ឋបាលកណ្តាល តំបន់ និងរដ្ឋបាលមូលដ្ឋានដែលទទួលការណែនាំតាមច្បាប់ជាតិ។

លើសពីនេះទៀត ច្បាប់សាសនា និងមិនមែនសាសនាអាចអនុវត្តរួមគ្នាដែលបង្កើតឲ្យមានភាពខុសគ្នាបន្ថែមទៀតរវាងប្រព័ន្ធអប់រំជាតិ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស។ ភាពខុសគ្នាអាចធ្វើឲ្យប៉ះពាល់ដល់កុមារី និងស្ត្រីយ៉ាងធ្ងន់ធ្ងរ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋត្រូវមានកាតព្វកិច្ចពិសេសដើម្បីការពារសិទ្ធិមនុស្ស ហើយរដ្ឋាភិបាលកណ្តាលត្រូវធានាពង្រីងសិទ្ធិទាំងនេះទូទាំងប្រទេស។

## ៣.១.២. លុបបំបាត់ឧបសគ្គហិរញ្ញវត្ថុ

ច្បាប់អន្តរជាតិគឺផ្អែកលើចំណេះដឹងដែលថា ការអប់រំមិនអាចជាកាតព្វកិច្ចដែលត្រូវធ្វើដោយខានមិនបាននោះទេ លុះណាតែការអប់រំគឺជាកាតព្វកិច្ចដែលត្រូវបំពេញដោយមិនគិតថ្លៃ។ ថ្លៃចំណាយដោយផ្ទាល់ និងដោយប្រយោលលើការអប់រំបង្កឧបសគ្គដល់កុមារជាច្រើនមិនឲ្យចូលរៀន ឬរៀនមិនបានចប់បឋមសិក្សា។ ទោះជាពាក្យទាំងពីរនៃការអប់រំនៅបឋមសិក្សា — ដោយកាតព្វកិច្ច និងមិនគិតថ្លៃ — ត្រូវបានលើកយកមកនិយាយជាមួយគ្នាគ្រប់ពេលនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិក៏ដោយ ក៏ពាក្យទាំងពីរនេះមិនទាក់ទងនឹងគោលនយោបាយរបស់ភ្នាក់ងារផ្តល់ជំនួយហិរញ្ញវត្ថុអន្តរជាតិដែរ ឬជាការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសនីមួយ ៗនោះដែរ។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិទាំងអស់តម្រូវឲ្យមានការអប់រំដោយកាតព្វកិច្ច និងមិនគិតថ្លៃ។ ហេតុផលនៅខាងក្រោយបញ្ហានេះគឺថា លុបបំបាត់ឧបសគ្គហិរញ្ញវត្ថុនឹងអាចធានាថា កុមារទាំងអស់នឹងទទួលបានការអប់រំដោយកាតព្វកិច្ច។ នៅពេលដែលគ្រួសារមិនអាចបង់ថ្លៃសំរាប់ការអប់រំបាន ការចូលរៀនរបស់កូនៗនឹងមិនអាចបង្ខំបានទេ។ ជាលទ្ធផល កុមារនឹងបន្តស្ថិតនៅក្រៅសាលា ហើយប្រទេសនឹងខ្វះពលរដ្ឋដែលមានចំណេះដឹង និងជំនាញ។

កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីដោះស្រាយបញ្ហានេះត្រូវបានខកខានដោយសារវិបត្តិសេដ្ឋកិច្ចក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ។ ការធ្លាក់ចុះនៃការបែងចែកថវិកាសំរាប់វិស័យអប់រំដោយហេតុថា ការក្បៀបសង្កត់ឲ្យសងបំណុល ជាពិសេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នាំឲ្យមានការយកថ្លៃសាលាជាផ្លូវការនៅក្នុងករណីមួយចំនួន។ ភាពមិនស៊ីចង្វាក់គ្នារបស់វិធីសាស្ត្រសកលលោកនាំឲ្យមានយុទ្ធសាស្ត្រពីរដាច់គ្នា។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានដាក់លក្ខខណ្ឌឲ្យយកថ្លៃសិក្សា (ដែលគេតែងហៅថា ការរួមចំណែកចេញថ្លៃសាលា) នៅក្នុងការអប់រំក្នុងការទទួលប្រាក់កម្ចីរបស់មូលនិធិនេះ។ ការធ្វើបែបនេះវាផ្ទុយទៅនឹងច្បាប់ប្រទេសនីមួយៗ និងច្បាប់អន្តរជាតិដែលកំណត់ថា ការអប់រំមិនត្រូវបានគិតថ្លៃទេ។ របាយការណ៍និយាយពីសិទ្ធិមនុស្សអន្តរជាតិបាននិយាយដដែល ៗដោយផ្អែកលើឯកសារយោងចំពោះកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធធ្វើជាហេតុផលនៃការយកថ្លៃសាលា។ ភាពខុសគ្នារវាងតម្រូវការច្បាប់ និងហិរញ្ញវត្ថុបានបង្ហាញដោយរបាយការណ៍ធានាគាពិភពលោកដែលពន្យល់ពីកង្វះខាតទិន្នន័យ :

"មានតែប្រទេសមួយចំនួនប៉ុណ្ណោះដែលប្រមូលទិន្នន័យទាក់ទងនឹងការចូលរួមបង់ថ្លៃសិក្សាឲ្យសាលារដ្ឋទោះបីជាការយកថ្លៃបែបនេះជារឿងទូទៅក៏ដោយ។ ហេតុផលនៃកង្វះទិន្នន័យគឺដោយសារតែការយកថ្លៃបែបនេះវាផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ឬដោយសារភាពខុសច្បាប់ខាងបច្ចេកទេស។"[១១]

11 World Bank - User Fees in Primary Education, Draft for Review, February 2002.

**វិបត្តិថវិកា**

បញ្ហាដែលប្រឈមមុខចំពោះអ្នកធ្វើយុទ្ធនាការពីសិទ្ធិមនុស្សគឺភាពខុសគ្នាធំធេងរវាងការបែងចែកធនធានសំរាប់សងបំណុល និងសំរាប់ការអប់រំ។ នៅឆ្នាំ ១៩៩១ ប្រទេសហ្វីលីពីនបានបែងចែកប្រាក់ចំនួន ៨៦ កោដិប៉េសូសំរាប់សងបំណុល និងប្រាក់ចំនួន ២៧ កោដិសំរាប់អប់រំ។ រដ្ឋធម្មនុញ្ញជាតិតម្រូវឲ្យរដ្ឋាភិបាលរៀបចំថវិកាច្រើនជាងគេបង្អស់សំរាប់វិស័យអប់រំ ហើយព្រឹទ្ធសភាមួយក្រុមឆ្ងល់ថា តើប្រាក់ទុកសំរាប់សងបំណុលដែលច្រើនជាងប្រាក់សំរាប់អប់រំចំនួន ៣ ដងនោះវាខុសនឹងរដ្ឋធម្មនុញ្ញឬអត់។ តុលាការបានរកឃើញថា ការពិតការអប់រំបានទទួលថវិកាច្រើនជាងក្រសួងផ្សេងទៀតរបស់រដ្ឋាភិបាលដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ហើយការទុកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់សំរាប់សងបំណុលគឺដើម្បីកិត្តិយសរបស់ជាតិ និងស្ថិរភាពសេដ្ឋកិច្ច។[១២]

ចាប់តាំងពីឈានចូលសហស្សវត្សរ៍ថ្មី ហាក់ដូចជាមានការកើនឡើងនូវនិន្នាការជាសកលឆ្ពោះទៅរកការព្រមព្រៀងជាសកលមួយដែលថា យ៉ាងហោចណាស់ការអប់រំនៅបឋមសិក្សាត្រូវតែមិនគិតថ្លៃ។ នៅទសវត្សរ៍ទី ៨០ ប្រាក់កម្ចីសំរាប់អប់រំដែលផ្តល់ដោយធនាគារពិភពលោកគឺសំរាប់បង្គ្រប់បន្ថែមប៉ុណ្ណោះ[១៣] ចំណែកឯថ្លៃសាលាជាច្រើនត្រូវបានគេប្រមូលពីសិស្ស ដែលធ្វើឲ្យសិស្សជាច្រើនមិនបានចូលរៀនដោយសារតែឪពុកម្តាយមិនអាចរកប្រាក់បង់ថ្លៃសាលាបាន។ នេះគឺជាបញ្ហាដែលទាំងសិទ្ធិមនុស្ស និងកម្មវិធីកាត់បន្ថយភាពក្រីក្រត្រូវជួបប្រទះ។[១៤]

ការសិក្សារបស់ធនាគារពិភពលោកស្តីការបង់ថ្លៃសាលាបង្ហាញនៅឆ្នាំ ២០០២ ថា ការយកថ្លៃសាលាមានការរីកដុះដាលជាងការស្មាន។ នៅអាស៊ីខាងត្បូង ការយកថ្លៃសាលាត្រូវបានចាត់ទុកជាទំលាប់វាពុំមែនជាករណីលើកលែងនោះទេ។ ចំណែកនៅអាស៊ីខាងកើត និងប៉ាស៊ីភិចវិញ ការយកថ្លៃសាលាត្រូវបានធ្វើឡើងនៅក្នុងទ្រង់ទ្រាយណាមួយនៅក្នុងប្រទេសជាច្រើន។[១៥] ការខិតខំប្រឹងប្រែងចេះតែបន្តក្នុងការបង្កើតឲ្យមានវិធីសាស្ត្ររួមដើម្បីលុបបំបាត់ឧបសគ្គហិរញ្ញវត្ថុសំរាប់ការអប់រំដោយកាតព្វកិច្ច។

ការលុបបំបាត់ការយកថ្លៃសាលាធ្វើឲ្យមានការកើនឡើងច្រើនភ្លាមៗនូវការចុះឈ្មោះចូលរៀននៅបឋមសិក្សានៅក្នុងប្រទេសមួយចំនួន (អ៊ូហ្គង់ដា តង់ហ្សានី និងកេនយ៉ា)។ ការលើកលែងបំណុលគឺជាយន្តការដែលនាំ ឲ្យមានការប្រែប្រួលបែបនេះ។ ការផ្តួចផ្តើមគំនិតក្នុងការបន្ធូរបន្ថយបំណុលដែលមិនមាននិរន្តរភាពធ្វើឲ្យមានការកើនឡើងថវិកាសំរាប់វិស័យអប់រំនៅប្រទេសដែលជំពាក់បំណុលច្រើន។ ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រស្នើឲ្យបែងចែកថវិកាបង្វែរពីការសងបំណុលមកប្រើនៅក្នុងវិស័យអប់រំវិញ ហើយជាទូទៅគេឃើញមានប្រាក់ដែលត្រូវសងបំណុលចំនួន ៤០ ភាគរយត្រូវបានប្រើប្រាស់នៅក្នុងវិស័យអប់រំ និងសុខាភិបាល។

---

12 Supreme Court of the Philippines - Guigona, Jr. v. Carague, G.R. No. 94571, 22 April 1991.

13 Commission on Human Rights - Progress Report of the Special Rapporteur on the right to education, U.N.Doc. E/CN.4/2000/6, paras. 45-55.

14 Commission on Human Rights - Annual Report of the Special Rapporteur on the right to education, U.N.Doc. E/CN.4/2001/52, paras. 31-41.

15 សំរាប់អាស៊ីខាងកើត និងប៉ាស៊ីភិក ការសិក្សាបង្ហាញថា ការយកថ្លៃសាលាកើតមាននៅប្រទេសចិន ឥណ្ឌូណេស៊ី ប៉ាពួញូហ្គីនេ កោះសូឡូម៉ុង និងវៀតណាម។ ការរួមចំណែករបស់ពុកម្តាយ និងសហគមន៍មាននៅប្រទេសកម្ពុជា ចិន ឡាវ ម៉ាឡេស៊ី ប៉ាពួញូហ្គីនេ កោះសូឡូម៉ុង ហ្វីលីពីន និងវៀតណាម។ World Bank - User Fees in Primary Education, Draft of February 2002.

### ៣.២. ធ្វើឲ្យមានតុល្យភាពរវាងការអប់រំដោយកាតព្វកិច្ច និងជំរើសរបស់ឪពុកម្តាយ

រដ្ឋាភិបាលមានតួនាទីធានាផ្តល់ការអប់រំ ប៉ុន្តែក៏ត្រូវគោរពសេរីភាពរបស់ឪពុកម្តាយនៅក្នុងការអប់រំកូនផងដែរ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិទាមទារឲ្យរដ្ឋគោរពសេរីភាពរបស់ឪពុកម្តាយ និងសហគមន៍ក្នុងការរៀបចំ និងដំណើរការសាលារៀន។ ហេតុផលគឺដើម្បីទប់ស្កាត់កុំឲ្យមានការផ្តាច់មុខលើវិស័យអប់រំ និងការពារកុំឲ្យមានការអប់រំច្រើនសណ្ឋានពេក។ ដោយហេតុថា មានការទាមទារឲ្យមានសិទ្ធិបែបនេះ រដ្ឋត្រូវជ្រើសរើសយកគំរូមួយក្នុងចំណោមគំរូទាំងពីរក្នុងការផ្តល់ការអប់រំ។ ទីមួយ រដ្ឋអាចផ្តល់ថវិកាដល់សាលាជាច្រើនដោយមិនចំាបាច់ចាត់ចែងសាលាទាំងនោះដោយផ្ទាល់ទេ។ ទីពីរ រដ្ឋអាចផ្តល់ថវិកា និងគ្រប់គ្រងសាលាប្រភេទណាមួយដោយខ្លួនឯង ដោយមិនមានផ្តល់ថវិកាដល់សាលាប្រភេទណាមួយផ្សេងទៀតទេ។

ការទាមទារឲ្យរដ្ឋជាអ្នកផ្តល់ថវិកា និងផ្តល់ការអប់រំគឺជាការវិវត្តថ្មីៗប៉ុណ្ណោះនៅក្នុងប្រវត្តិសាស្ត្រនៃការអប់រំ។ ការអប់រំទ្រង់ទ្រាយតូចដែលមានចងក្រងនៅក្នុងបញ្ញត្តិបុរេរដ្ឋត្រូវបានបង្ហាញដោយគំរូច្រើនបែបដែលមានស្រាប់។ និន្នាការនៃការកែប្រែវិស័យអប់រំឲ្យទៅជាឯកជននៅទសវត្សរ៍ ៩០ គឺជាការរំលឹកឡើងវិញអំពីអ្វីដែលកើតមានកាលពីអតីតកាល ដែលនៅពេលនោះ ការអប់រំសំរាប់តែមនុស្សមួយចំនួនតូចប៉ុណ្ណោះ។ ការមានស្របគ្នានៃការអប់រំដែលមិនគិតថ្លៃ (រដ្ឋ) និងគិតថ្លៃ (ឯកជន) ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ហើយច្បាប់ជាច្រើនយកចិត្តទុកដាក់លើការប្រើប្រាស់ថវិការដ្ឋសំរាប់ជួយបង្កើត និងដំណើរការសាលារៀន។ នេះគឺជាសិទ្ធិដែលត្រូវបានធានានៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ទាក់ទងដល់ប្រាក់ឧបត្ថម្ភសំរាប់សាលាមិនមែនរដ្ឋ មានគោលនយោបាយខុសគ្នាយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយទៀត។ តាមការពិត មានភាពខុសគ្នាយ៉ាងខ្លាំងក្នុងបំណែងចែកសាលា និងបំណែកចែករវាងសាលារដ្ឋ និងសាលាឯកជន។ ការបែងចែកដែលរៀបចំឡើងដោយអង្គការ យូណេស្កូ ដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងព័ត៌មានស្ថិតិអប់រំ បែងចែកសាលាទៅជាសាលាដែលគ្រប់គ្រងដោយរដ្ឋ និងគ្រប់គ្រងដោយឯកជន។ "ដូច្នេះ សាលាដែលទទួលជំនួយពីរដ្ឋនឹងត្រូវបានគេចាត់ទុកថាជាសាលាឯកជន បើសិនជាសាលានោះត្រូវគ្រប់គ្រងដោយឯកជន"។[១៦] ផ្ទុយទៅវិញ តុលាការអង់គ្លេសបានបែងចែកសាលាថាជាសាលារដ្ឋ ឬឯកជនដោយប្រើប្រាស់ប្រភព ថវិកាជាលក្ខណៈវិនិច្ឆ័យសំខាន់ជាងគេ។ បើសិនជាសាលាទទួលការឧបត្ថម្ភពីរដ្ឋ វាគឺជាសាលារដ្ឋ ទោះជាអ្នកណាគ្រប់គ្រងក៏ដោយ។[១៧]

ប្រវត្តិសាស្ត្របង្ហាញថា ការអប់រំត្រូវបានកំណត់ថា ជាភារកិច្ច មិនមែនជាសិទ្ធិទេ កាលពីយូរលុងមកហើយ។ សេចក្តីប្រកាសសិទ្ធិកុមារនៅឆ្នាំ ១៩៥៩ គឺជាមូលដ្ឋានគ្រឹះដែលកំណត់ឲ្យកុមារទទួលការអប់រំ។[១៨] ចក្ខុវិស័យនៅពេលនោះចាត់ទុកកុមារជាអ្នកទទួលការអប់រំដោយអសកម្ម។ ក្រោយមក ការចាត់ទុកការអប់រំជារបស់ខ្វះមិនបាន បានបង្ហាញអំពីតួនាទីរបស់រដ្ឋក្នុងការធានាផ្តល់ឱកាសអប់រំដល់កុមារគ្រប់ៗរូប។ ប្រទេសមួយចំនួនអនុញ្ញាតឲ្យមានការអប់រំក្រៅពីការអប់រំក្នុងប្រព័ន្ធ។ ឧទាហរណ៍ ឪពុកម្តាយបានទទួលការអនុញ្ញាតឲ្យ

---

16 UNESCO - 1998 World Education Report, Paris, 1999, p. 118.

17 National Union of Teachers v. Governing Body of St. Mary's Church of England Aided School, [1995] ICR 317, EAT [1997] IRLR 242 (CA); R. v. Haberdasher's Aske;s Hatcham Trust, ex parte T [1995] ELR 350; EA 1996, ss 482 (1) (b), (3); 483.

18 United Nations General Assembly resolution 1386 (XIV) of 20 November 1959, Principle 7.

បង្រៀនកូននៅផ្ទះ។ ភាពស្មុគស្មាញដែលមាននៅក្នុងការអនុវត្តការអប់រំដោយកាតព្វកិច្ច ដោយគោរពផលប្រយោជន៍ខុសៗគ្នារបស់ភាគីសំខាន់ៗត្រូវបានបង្ហាញថ្មីៗនេះនៅប្រទេសសឹង្ហបុរី :

"បន្ទាប់ពីពិភាក្សាជាមួយនឹងថ្នាក់ដឹកនាំសហគមន៍ ក្រុមគោលដៅ និងសមាជិកតំណាងសាធារណៈជន រដ្ឋាភិបាលបានសំរេចដាក់ការអប់រំនៅបឋមសិក្សារយៈពេល ៦ ឆ្នាំ នៅក្នុងសាលារដ្ឋថាជាការអប់រំដោយកាតព្វកិច្ចដោយចូលជាធរមានពីខែមករា ឆ្នាំ ២០០៣ ចាប់ផ្តើមពីក្រុមដែលចូលរៀន នៅបឋមសិក្សា ១ នៅឆ្នាំនោះ។ ច្បាប់ស្តីពីការអប់រំដោយកាតព្វកិច្ចត្រូវបានអនុម័តដោយសភាសឹង្ហបុរីនៅខែតុលា ឆ្នាំ ២០០០។ ក៏ប៉ុន្តែតាមការពិតជាក់ស្តែង នៅក្នុងប្រទេសសឹង្ហបុរី ការលើកលែងចំពោះការអប់រំដោយកាតព្វកិច្ចនេះត្រូវអនុវត្តចំពោះកុមារ ៤ ក្រុម :

***(ក) សិស្សរបស់សាលាសាសនាអ៊ីស្លាម*** : សាលាអ៊ីស្លាមមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតបញ្ញាជនសាសនា និងគ្រូសាសនាសំរាប់សហគមន៍ជនជាតិអ៊ីស្លាម។ សាលាសាសនាអ៊ីស្លាមនេះគិតថា ការបណ្តុះបណ្តាលបញ្ញជន និងគ្រូត្រូវចាប់ផ្តើមតាំងពីអាយុក្មេង។ ហើយពួកគេនឹងមិនអាចទាក់ទាញសិស្សឲ្យរៀននៅមធ្យមសិក្សាបានទេ បើសិនជាសិស្សត្រូវរៀនសាលារដ្ឋនៅបឋមសិក្សាដោយខានមិនបាននោះ។

***(ខ) សិស្សនៅសាលាសាសនាសានយូ*** : សាលាសាសនាសានយូជាកម្មសិទ្ធិ និងគ្រប់គ្រងដោយបេសកជនសាសនា សឹង្ហបុរីឈ្មោះ Seventh Day ... គោលបំណងរបស់សាលាគឺផ្តល់ការអប់រំបែបសាសនាគ្រិះឲ្យស៊ីគ្នាជាមួយនឹងប្រព័ន្ធអប់រំសឹង្ហបុរី។ ដោយហេតុថាសាលាធ្លាប់ផ្តល់ការអប់រំដល់ប្រជាជនសឹង្ហបុរីជាច្រើននាក់ចាប់តាំងពីសាលាកើតឡើងមក ប្រជាជនទទួលស្គាល់សាលានេះគ្រប់ៗគ្នា។ ដូច្នេះ សិស្សសឹង្ហបុរីរៀននៅបឋមសិក្សាក្នុងសាលានេះក៏ត្រូវបានលើកលែងចេញពីការអប់រំដោយកាតព្វកិច្ចដែរ។ សាលាដូចជាសាលាសាសនាខាងលើត្រូវបំពេញឲ្យបាននូវស្តង់ដាអប្បបរមានៅបឋមសិក្សា (ដោយការប្រលងបញ្ចប់បឋមសិក្សា)។

***(គ) កុមារទទួលការអប់រំនៅតាមផ្ទះ*** : ឪពុកម្តាយមួយចំនួនតូចមានទស្សនៈរឹងមាំក្នុងការចិញ្ចឹមបីបាច់ និងអប់រំកូន។ ឪពុកម្តាយសំរេចបង្រៀនកូននៅផ្ទះ ដោយប្រើប្រាស់កម្មវិធីសិក្សាដែលគេរៀបចំសំរាប់អ្នកសិក្សានៅផ្ទះ។ ដោយហេតុថា ឪពុកម្តាយមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាលកូននៅតាមគ្រួសារ កុមារទាំងនេះក៏ត្រូវបានទទួលការលើកលែងពីការសិក្សាដោយខានមិនបានដែរ។ ប៉ុន្តែ ឪពុកម្តាយត្រូវធ្វើយ៉ាងណាឲ្យការបង្រៀននៅតាមផ្ទះឆ្លើយតបទៅនឹងគោលដៅ ២ យ៉ាងរបស់ក្រសួងអប់រំដែរ។ គោលដៅទាំង ២ នេះគឺ :

*(១) ផ្តល់ឲ្យកុមារនូវចំណេះដឹងទូទៅ ដែលនឹងក្លាយជាចំណេះដឹងមូលដ្ឋានសំរាប់បន្តការសិក្សាដើម្បីរៀបចំកុមារឲ្យសមស្របសំរាប់សេដ្ឋកិច្ចដែលផ្អែកលើចំណេះដឹងជាមូលដ្ឋាន។*

*(២) ផ្តល់ឲ្យកុមារនូវបទពិសោធន៍សិក្សាទូទៅដែលនឹងជួយកសាងការកត់សំគាល់អត្តសញ្ញាណជាតិ។*

គេក៏ទាមទារឲ្យឪពុកម្តាយផ្តល់ព័ត៌មានថ្មីៗលើកម្មវិធីសិក្សា និងលទ្ធផលអប់រំនៃកម្មវិធីអប់រំនៅតាមផ្ទះ។ ការរីក ចំរើនរបស់អ្នកសិក្សានៅតាមផ្ទះត្រូវបានគេតាមដានត្រួតពិនិត្យដោយយកចិត្តទុកដាក់។ សិស្សតាមផ្ទះនឹងត្រូវប្រលងនៅពេលណាមួយនៅបឋមសិក្សា និងនៅ PSLE. ពួកគេត្រូវតែមានស្តង់ដាដូច PSLE ដូចកុមារដែលរៀននៅសាលាសាសនាសានយូរដែរ។ ក្រសួងអប់រំរក្សាសិទ្ធិដកការយល់ព្រមពីការលើកលែងពីការអប់រំដោយកាតព្វកិច្ចវិញនៅពេលណាក៏បាន។ ការទាមទារតឹងតែងសំរាប់អ្នករៀននៅផ្ទះ គឺដើម្បីចៀសវាងឪពុកម្តាយដែលមិនមានការទទួលខុសត្រូវ ហើយគេចវៀសពី ការអប់រំដោយកាតព្វកិច្ច។

***(ឃ) កុមារដែលមានតម្រូវការពិសេស*** : ជំរើសជាច្រើនមានសំរាប់ការអប់រំសំរាប់កុមារដែលមានតម្រូវការពិសេស។ កុមារដែលពិការវិញ្ញាណណាមួយតិចតួច តែអាចរៀនជាមួយសិស្សធម្មតាបាន រៀននៅសាលាទូទៅធម្មតា តែដោយមានធនធានសម្ភារពិសេសបន្ថែមទៀត។ កុមារដែលពិការខ្លាំងត្រូវរៀនដាច់ដោយឡែកយ៉ាងពិសេសដែលរៀបចំឡើងដោយអង្គការសុខុមាលភាពស្ម័គ្រចិត្ត ដោយមានជំនួយពីក្រសួងអប់រំ និងក្រុមប្រឹក្សាជាតិរបស់សេវាសាធារណៈ។ ចំណែកកុមារដែលពិការសមត្ថភាពសិក្សាអាចអភិវឌ្ឍន៍សក្តានុភាពរបស់គេបានពេញលេញ បើសិនជាគេរៀននៅក្នុងសាលាពិសេស។ ការបង្ខំឪពុកម្តាយឲ្យទទួលយកការអប់រំដោយកាតព្វកិច្ចហាក់ដូចជាហួសហេតុពេកសំរាប់ក្រុមកុមារដែលមានតម្រូវការពិសេស។ ដូច្នេះគេបានសំរេចថា កុមារដែលមានតម្រូវការពិសេស ហើយមិនអាចរៀននៅសាលារដ្ឋធម្មតាបានត្រូវទទួលបានការអនុញ្ញាតឲ្យរួចពីការអប់រំដោយកាតព្វកិច្ចដោយស្វ័យប្រវត្តិ។"[១៩]

[19] CRC/C/51/Add. 8 of 17 March 2003, para.421 - 424

**សេរីភាព ក្នុងការជ្រើសរើសរបស់ឪពុកម្តាយ**

សេរីភាពនៃការជ្រើសរើសរបស់ឪពុកម្តាយក្នុងការសំរេចជ្រើសរើសយកប្រភេទនៃការអប់រំសំរាប់កូន (សាលារដ្ឋ ឯកជន និងការបង្រៀនទៅតាមផ្ទះ) គឺជាចំណុចផ្ទុយគ្នារាំងមិនឲ្យមានការអប់រំរបស់រដ្ឋតែមួយគត់ដែលកើតចេញពីស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ។ លើសពីនេះទៀត កុមារត្រូវបានគេចាត់ទុកថាជាទ្រព្យសម្បត្តិរដ្ឋ ឬរបស់ឪពុកម្តាយ ដោយមិនអនុញ្ញាតឲ្យកុមារមានសិទ្ធិចូលរួមនៅក្នុងការសំរេចចិត្ត។ សិទ្ធិបែបនេះត្រូវទទួលស្គាល់ដោយអនុសញ្ញាសិទ្ធិកុមានៅពេលនេះ បើទោះជាអនុសញ្ញានោះមិនទាន់ត្រូវបានយកទៅអនុវត្តជាក់ស្តែងនៅតាមបណ្តាប្រទេសជាច្រើនក៏ដោយ។ ករណីដែលកុមារមានសិទ្ធិជ្រើសរើសសាលាត្រូវបានបញ្ជាក់ច្បាស់ ឬនៅកន្លែងដែលច្បាប់ប្រគល់សិទ្ធិឲ្យកុមារប្រើប្រាស់នីតិវិធីតុលាការទាក់ទងនឹងការអប់រំរបស់កុមារត្រូវលើកយកមកនិយាយនៅក្នុងឯកសារនេះ។

ការអប់រំដោយកាតព្វកិច្ចនៅក្នុងការអនុវត្តជាក់ស្តែងគឺជាសិទ្ធិ និងកាតព្វកិច្ចរបស់កុមារ។ កាតព្វកិច្ច នេះត្រូវបានគេទទួលយកដើម្បីបំរើផលប្រយោជន៍របស់កុមារឲ្យបានល្អប្រសើរបំផុត។ ទោះជាយ៉ាងនេះក្តី តម្រូវការដែលទាមទារឲ្យមានការការពារសិទ្ធិមនុស្សនៅក្នុងការអប់រំ និងការលេចឡើងនូវសិទ្ធិកុមារកំពុងតែមានការកែប្រែការអប់រំដោយកាតព្វកិច្ចយ៉ាងយឺតយ៉ាវបំផុត។

ក្នុងការអនុវត្តជាក់ស្តែង ច្បាប់ក្នុងស្រុកតែងឆ្លុះបញ្ចាំងទស្សនៈដែលថា ការអប់រំដោយកាតព្វកិច្ចគឺមានន័យលើសពីឱកាសសំរាប់រដ្ឋប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីកំណត់ បង្ខំ និងត្រួតពិនិត្យដំណាក់កាលដំបូងនៃការអប់រំ ហើយសិទ្ធិទទួលការអប់រំតែងត្រូវបានគេមើលរំលង។ ដើម្បីធានាកុំឲ្យរដ្ឋប្រើប្រាស់អំណាចខុសវិធានការសិទ្ធិមនុស្សគឺជាវិធីសាស្ត្រចាំបាច់ដែលត្រូវយកមកសំអាង។ វិធានការនេះគឺដើម្បីធ្វើឲ្យមានតុល្យភាពសិទ្ធិរបស់រដ្ឋក្នុងការបង្ខំកុមារឲ្យទទួលការអប់រំ និងសិទ្ធិរបស់ឪពុកម្តាយដែលចង់ផាកចេញពីការអប់រំដោយកាតព្វកិច្ច។

រដ្ឋធម្មនុញ្ញ និងច្បាប់ជាតិដើរតាមវិធីផ្សេងៗគ្នានៅក្នុងន័យនេះ។ ខ្លះកំណត់ការអប់រំថា ជាសិទ្ធិ និងកាតព្វកិច្ច ហើយខ្លះទៀតថាជាសិទ្ធិតែប៉ុណ្ណោះ ហើយឯខ្លះទៀតចាត់ទុកថាជាសេរីភាពរបស់សហគមន៍ ឬគ្រួសារដែលត្រូវបង្រៀនកូន។ ការធ្វើឲ្យការអប់រំជាកាតព្វកិច្ចដោយខានមិនបានរបស់កុមារគ្រប់រូបក្នុងអាយុកំណត់ច្បាស់លាស់មួយ —នៅក្នុងការអនុវត្តជាក់ស្តែង មិនមែននៅតែក្នុងច្បាប់នោះទេ — អាស្រ័យលើថា តើមានសាលាឬអត់ និងការលុបបំបាត់រាល់ឧបសគ្គទាំងអស់ក្នុងការចូលរៀន និងការគិតគូរអំពីគុណភាព និងគោលបំណងនៃការអប់រំ។ វិធីសាស្ត្រ និងបទពិសោធន៍របស់ប្រទេសនីមួយៗ ខុសគ្នាខ្លាំងណាស់នៅក្នុងន័យនេះ។

**តារាងទី ៦ : រយៈពេលកំណត់តាមច្បាប់សំរាប់ការអប់រំដោយកាតព្វកិច្ច**

| អាយុ | ប្រទេស |
|---|---|
| 13 | Netherlands |
| 12 | Belgium, Brunei Darussalam, Germany, St Kitts and Nevis |
| 11 | Antigua and Barbuda, Armenia, Azerbaijan, Barbados, British Virgin Islands, Dominica, Grenada, Israel, Kazakhstan, Malta, Moldova, United Kingdom |
| 10 | Argentina, Australia, Belize, Canada, Congo, Costa Rica, Dominican Republic, Democratic People's Republic of Korea, Ecuador, France, Gabon, Hungary, Iceland, Kyrgyzstan, Liberia, Monaco, Namibia, New Zealand, Norway, Seychelles, Spain, St Lucia, St Vincent and the Grenadines, Venezuela, USA |
| 9 | Algeria, Austria, Bahamas, Bahrain, Belarus, Cambodia, China, Comoros, Cook Islands, Cuba, Cyprus, Czech Republic, Denmark, El Salvador, Estonia, Finland, Georgia, Greece, Hong Kong, Indonesia, Ireland, Japan, Jordan, Kiribati, Lebanon, Libya, Lithuania, Luxembourg, Mali, Netherlands Antilles, Portugal, Republic of Korea, Russia, Sierra Leone, Slovakia, South Africa, Sri Lanka, Sweden, Switzerland, Tajikistan, Tunisia, Ukraine, Yemen |
| 8 | Albania, Angola, Bolivia, Brazil, Bulgaria, Chile, Croatia, Egypt, Fiji, FYROM, Ghana, Guyana, India, Italy, Kenya, Kuwait, Latvia, Malawi, Mongolia, Niger, Poland, Romania, Samoa, San Marino, Slovenia, Somalia, Sudan, Tonga, Turkey, Yugoslavia, Zimbabwe |
| 7 | Burkina Faso, Eritrea, Lesotho, Mauritius, Mozambique, Swaziland, Tanzania, Trinidad and Tobago, Tuvalu, Zambia Afghanistan, |
| 6 | Benin, Burundi, Cameroon, Cape Verde, Central African Republic, Chad, Cote d'Ivoire, Djibouti, Ethiopia, Guatemala, Guinea, Guinea-Bissau, Haiti, Honduras, Iraq, Jamaica, Madagascar, Mauritania, Mexico, Morocco, Nicaragua, Nigeria, Panama, Paraguay, Peru, Philippines, Rwanda, Senegal, Suriname, Syria, Thailand, Togo, United Arab Emirates, Uruguay, Vanuatu |
| 5 | Bangladesh, Colombia, Equatorial Guinea, Iran, Laos, Macao, Myanmar, Nepal, Viet Nam |
| 4 | Sao Tome and Principe |

**ប្រភព : របាយការណ៍រដ្ឋាភិបាល និងយូណេស្កូនៅក្នុងសន្និសញ្ញាសិទ្ធិមនុស្ស**

យូណេស្កូបានប្រមូលទិន្នន័យទាក់ទងនឹងរយៈពេលអប់រំដោយកាតព្វកិច្ច ហើយទិន្នន័យនេះបង្ហាញពីទស្សនៈសកលដូចដែលបានបង្ហាញនៅក្នុងតារាងទី ៦។ នៅពេលដែលការអប់រំគឺជាកាតព្វកិច្ចដោយខានមិនបាននៅក្នុងប្រទេសជាច្រើននៅលើពិភពលោករយៈពេលខុសគ្នាពី ៤ ទៅ ១៣ ឆ្នាំ បង្ហាញពីទឹកចិត្ត និងសមត្ថភាពខុសគ្នារបស់រដ្ឋាភិបាលក្នុងការធានាថា កុមារទាំងអស់ និងយុវជនត្រូវបញ្ចប់ការអប់រំក្នុងរយៈពេលសិក្សាមួយច្បាស់លាស់។

វាជាការសំខាន់ណាស់ដែលត្រូវចងចាំថា សិទ្ធិរបស់កុមារត្រូវបានដាក់ចូលក្នុងច្បាប់អន្តរជាតិក្រោយគេ ដោយមានអនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានដាក់ចូលនៅឆ្នាំ ១៩៨៩។ បច្ចុប្បន្ន កុមារត្រូវបានចាត់ទុកថាជាអ្នកសំខាន់ក្នុងការទទួលការអប់រំ ក៏ជាអ្នកដែលត្រូវបំពេញកាតព្វកិច្ចអប់រំដោយខានមិនបានដែរ។ ដោយមានករណីលើកលែងតិចតួចប៉ុណ្ណោះ កុមារមិនមែនជាអ្នកធ្វើការសំរេចចិត្តលើការអប់រំសំរាប់ខ្លួនឯងទេ។ ការសំរេចចិត្តទាំងនេះទាក់ទងជាមួយរដ្ឋ ឪពុកម្តាយរបស់កុមារ អ្នកអប់រំ និងគ្រូ។ នៅពេលការសំរេចចិត្តត្រូវបែងចែករវាងឪពុកម្តាយ និងរដ្ឋ ភាគីនីមួយៗអះអាងថា ជាអ្នកដឹងច្បាស់ពីផលប្រយោជន៏របស់កុមារតែជាញឹកញាប់ពួកគេតែងមានការខ្វែងគំនិតលើបញ្ហាថា តើអ្វីជាផលប្រយោជន៏របស់កុមារបានពីការអប់រំ។

**ការអប់រំដោយកាតព្វកិច្ច និងសេរីភាពក្នុងការជ្រើសរើសរបស់ឪពុកម្តាយ**

ដូចដែលតារាងទី ៧ បង្ហាញ ការគោរពសិទ្ធិឪពុកម្តាយនៅក្នុងការជ្រើសរើសការអប់រំសំរាប់កូនដោយអនុលោមទៅតាមជំនឿសាសនា និងទស្សនៈត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសន្និសញ្ញាសិទ្ធិមនុស្សទាំងអស់។ ទោះបីជាមានការស្រុះស្រួលគ្នាយ៉ាងនេះក្តី កាតព្វកិច្ចក្នុងការផ្តល់ការអប់រំសំរាប់ទាំង អស់គ្នានៅតែជាកាតព្វកិច្ចរបស់រដ្ឋ។ រដ្ឋអាចធានាសេរីភាពនៃការអប់រំដោយការផ្តល់ប្រាក់ឧបត្ថម្ភតែមិនចាត់ចែងសាលាដែលមានលក្ខណៈខុសគ្នានោះទេ។

## ភាពទី ៧ : ការធានាជាសកលដល់សេរីភាពនៃការជ្រើសរើសរបស់ឪពុកម្តាយ

***សេចក្តីប្រកាសរួម (១៩៤៨)***

*ឪពុកម្តាយមានសិទ្ធិមុនក្នុងការជ្រើសរើសប្រភេទនៃការអប់រំសំរាប់កូន*

***អនុសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ (១៩៦០)***

*ភាគីរដ្ឋនៅក្នុងអនុសញ្ញានេះយល់ព្រមថា :*

*(ខ) វាជាការសំខាន់ក្នុងការគោរពសេរីភាពរបស់ឪពុកម្តាយ ... ទីមួយក្នុងការជ្រើសរើសស្ថាប័នសិក្សាក្រៅពីស្ថាប័នដែលគ្រប់គ្រងដោយរដ្ឋ តែអនុលោម .... តាមស្តង់ដាអប់រំអប្បបរមា និងជាពិសេស .... ទីពីរធានាថា ... ការអប់រំ សីលធម៌ និងសាសនាដល់កូនដោយអនុលោមតាមជំនឿរបស់កុមារ។*

***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិវប្បធម៌ សង្គមកិច្ច និងសិទ្ធិសេដ្ឋកិច្ច (១៩៦៦)***

*ភាគីរដ្ឋនៅក្នុងកតិកាសញ្ញានេះត្រូវគោរពសេរីភាពរបស់ឪពុកម្តាយ ... ក្នុងការជ្រើសរើសសាលាសំរាប់អប់រំកូនជាជាងសាលាដែលរដ្ឋផ្តល់ឲ្យតែសាលាដែលឪពុកម្តាយរើសយកនោះត្រូវតែឆ្លើយតបទៅនឹងស្តង់ដាអប់រំអប្បបរមាដែលកំណត់ដោយរដ្ឋ។ ផ្តល់សេរីភាពឲ្យឪពុកម្តាយជ្រើសរើសសាលាដើម្បីឲ្យកូនរៀនសីលធម៌ និងសាសនាដោយអនុលោមទៅតាមជំនឿសាសនារបស់កុមារ។*

*មិនមានផ្នែកណាមួយនៃមាត្រានេះត្រូវបានគេបកស្រាយក្នុងន័យរំខានដល់សេរីភាពរបស់បុគ្គល និងអង្គការដើម្បីបង្កើត និងដឹកនាំស្ថាប័នអប់រំនោះទេ។*

***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ (១៩៦៦)***

*ភាគីរដ្ឋនៅក្នុងកតិកាសញ្ញានេះត្រូវគោរពសេរីភាពរបស់ឪពុកម្តាយ ............. ដើម្បីធានាការអប់រំសាសនា និងសីលធម៌ដល់កូនដោយអនុលោមតាមជំនឿសាសនារបស់កុមារ។*

***អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩)***

*គ្មានផ្នែកណាមួយនៃ (មាត្រាទី ២៨ និង ២៩) ត្រូវបានគេបកស្រាយក្នុងន័យរំខានដល់សេរីភាពរបស់បុគ្គល និងអង្គការដើម្បីបង្កើត និងដឹកនាំស្ថាប័នអប់រំនោះទេ។*

សិទ្ធិទទួលការអប់រំទាមទារឲ្យមានច្បាប់របស់រដ្ឋ ពីព្រោះរដ្ឋជាអ្នកទទួលខុសត្រូវធានាថា រាល់ស្ថាប័នអប់រំទាំងអស់ត្រូវអនុលោមតាមស្តង់ដាដែលបានកំណត់។ ការប្រើប្រាស់សេរីភាពក្នុងការជ្រើសរើសរបស់ឪពុកម្តាយក្នុងការអប់រំកូនទាមទារឲ្យមានការបង្កើតសាលាប្រភេទផ្សេងៗ។ ស្តង់ដាអប់រំនេះត្រូវតែអនុវត្តនៅគ្រប់សាលាទាំងអស់ដើម្បីធានាគុណភាពអប់រំរបស់រដ្ឋ ក៏ដូចជាឯកជន និងដើម្បីការពារកុមារកុំឲ្យមានការរំលោភបំពាន។